**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ✓ មស.

## សារលិខិតជូនពរ

**សូមគោរពជូន**
**សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**សម្តេចពិជ័យសេនា ជាទីគោរពដ៏ខ្ពង់ខ្ពស់**!

ក្នុងឱកាសនៃពិធីបុណ្យចូលឆ្នាំសកល ឆ្នាំ២០២២ ខាងមុខនេះ ខ្ញុំបាទនិងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការទាំងអស់នៃក្រសួងមុខងារសាធារណៈ សូមលើកហត្ថប្រណមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី វត្ថុសក្តិសិទ្ធិទាំងអស់ក្នុងលោក និងទេវតារក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា សូមព្រះអង្គតាមជួយបីបាច់ថែរក្សា ប្រោះព្រំ ប្រទានពរជ័យសិរីសួស្តី បវរមហាប្រសើរជូន **សម្តេចពិជ័យសេនា និងលោកជំទាវ**។

ក្នុងឱកាសដ៏មហាប្រសើរថ្លៃថ្លានេះដែរ យើងខ្ញុំទាំងអស់គ្នាសូមសម្តែងនូវមនោសញ្ចេតនាគោរពនិងដឹងគុណដោយស្មោះអស់ពីដួងចិត្តចំពោះទឹកចិត្តដ៏ថ្លៃថ្លា និងសកម្មភាពដ៏ឧត្តុង្គឧត្តមរបស់ **សម្តេចពិជ័យសេនា** ក្នុងបេសកកម្មដឹកនាំក្រសួងការពារជាតិ ដើម្បីបន្តរក្សាការពារសុខសន្តិភាព ស្ថិរភាព សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ និងអភិវឌ្ឍវិស័យការពារជាតិ សំដៅចូលរួមជាឧត្តមប្រយោជន៍ជាតិនិងប្រជាជននៅទូទាំងប្រទេស។

ឆ្លៀតក្នុងឱកាសដ៏រីករាយនិងថ្លៃថ្លានេះ យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំងអស់ក្នុងលោក សូមប្រោសប្រទានជូន **សម្តេចពិជ័យសេនា និងលោកជំទាវ ព្រមទាំងបុត្រា បុត្រី និងចៅប្រុស ចៅស្រី** សូមមានសុខភាពល្អបរិបូរណ៍ និងទទួលបាននូវព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចពិជ័យសេនា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់និងជ្រាលជ្រៅបំផុតពីយើងខ្ញុំទាំងអស់គ្នា៕ ៚

ថ្ងៃ ពុធ ៣រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២២ខែ ធ្នូ ឆ្នាំ២០២១
**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

ព្រុំ សុខា

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh